# វៀតណាមទទួលស្គាល់ថាខ្លួនបានជីកស្រះ សង់ប៉ុស្តិ៍យោធា និងធ្វើផ្លូវចូលដីកម្ពុជា

ដោយ៖ ស៊ុន ណារិន | ថ្ងៃសុក្រ ទី10 កក្កដា 2015, 10:44 AMUPDATED



អនុរដ្ឋមន្ត្រីការបរទេសវៀតណាម លោក Ho Xuan Son និងប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជា លោក វ៉ា គឹមហុង(រូបថតដោយទេព សូនី)

អនុរដ្ឋមន្ត្រីការបរទេសវៀតណាម លោក Ho Xuan Son បានទទួលស្គាល់ថាវៀតណាមបានជីកស្រះ សង់ប៉ុស្តិ៍យោធា និងធ្វើផ្លូវចូលដីកម្ពុជា ដូចកំណត់ទូតរបស់ក្រសួងការបរទេសកម្ពុជាដែលបានតវ៉ាកាលពីកន្លងទៅ។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសកម្ពុជា ចេញផ្សាយនៅថ្ងៃសុក្រនេះ ឲ្យដឹងថាក្រសួងការបរទេសកម្ពុជាបានលើកឡើងពីកំណត់ទូតនៅក្នុងកិច្ចប្រជុំ៣ថ្ងៃ ដែលបានបញ្ចប់កាលពីថ្ងៃព្រហស្បតិ៍។ សេចក្តីប្រកាសបន្តថាទាក់ទងនឹងបញ្ហាការជីកស្រះនៅខេត្តរតនគិរី ចន្លោះបង្គោលព្រំដែនលេខ៣០និង៣០ កម្ពុជាបានស្នើឲ្យលុបស្រះចំនួន៨កន្លែង តាមកំណត់ទូតកាលពីថ្ងៃតី១២ និងថ្ងៃទី១៤ ខែមិថុនា។ ជាការឆ្លើយតប អនុរដ្ឋមន្ត្រីការបរទេសវៀតណាមបានសន្យាថានឹងលុបស្រះចំនួន៣ ចំណែកស្រះ៥ទៀត ក្រុមបច្ចេកទេសចម្រុះនៃគណៈកម្មការព្រំដែននៃប្រទេសទាំងពីរ នឹងចុះទៅពិនិត្យមើលជាក់ស្តែង តែថាក្នុងនោះមានស្រះចំនួនពីរជាស្រះចាស់យូរមកហើយ។

បើតាមសេចក្តីប្រកាសព័ត៌មាន ទាក់ទងនឹងការសង់ប៉ុស្តិ៍យោធាក្បែរភូមិព្រែកស្បូវ ឃុំសំពៅលូន ស្រុកកោះធំ ខេត្តកណ្តាល ភាគីកម្ពុជាបានស្នើភាគីវៀតណាមផ្អាកសាងសង់ប៉ុស្តិ៍យោធាជាបន្ទាន់ដែលក្រសួងបានធ្វើកំណត់ទូតតវ៉ា២ដង កាលពីថ្ងៃទី៨ និងថ្ងៃទី១៧ ខែមិថុនា។ អនុរដ្ឋមន្ត្រីការបរទេសវៀតណាមបានបញ្ជាក់ថាបានផ្អាកការសាងសង់នេះ។ ចំណែកកំណត់ទូតតវ៉ារឿងការធ្វើផ្លូវនៅចន្លោះបង្គោលព្រំដែនលេខ១៩៤-២០៣ និង២១១-២១៣ និងលេខ២១៣-២២៧ នៅស្រុកចន្ទ្រា និងស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដែលក្រសួងបានធ្វើកំណត់ទូតតវ៉ាកាលពីថ្ងៃទី០១ ខែកក្កដា អនុរដ្ឋមន្ត្រីការបរទេសវៀតណាមបានប្រាប់ថាបានបញ្ជាឲ្យផ្អាកការសាងសង់ហើយ។

អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក ជុំ សន្ទរី មានប្រសាសន៍ថារដ្ឋលេខាធិការក្រសួងការបរទេស លោក ឡុង វិសាលោ បានលើកឡើងពីកំណត់ទូតកម្ពុជាទៅភាគីវៀតណាមនៅក្នុងកិច្ចប្រជុំបីថ្ងៃកាលពីកន្លងទៅ។ លោកបន្តថាការដែលមិនបញ្ចូលការឆ្លើយតបនេះទៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មការ ចម្រុះព្រំដែន ដោយសារនេះជាសមត្ថកិច្ចផ្សេងគ្នា។

នៅពេលសួរថាតើនេះជាការទទួលស្គាល់របស់វៀតណាមថាបានរំលោភយកដីកម្ពុជា លោក ជុំ សន្ទរី មានប្រសាសន៍ថា«*ខ្ញុំមិនបានចូលជ្រៅទៅបកស្រាយដល់ហ្នឹងទេ តែចង់ឲ្យមានការឆ្លើយតបពីភាគីវៀតណាម*»។ លោកបន្តថាការចុះពិនិត្យ និងតាមដានលើការអនុវត្តការសន្យានេះ អាស្រ័យលើក្រុមបច្ចេកទេសចម្រុះរបស់ប្រទេសទាំងពីរ។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន ដែលបានរកឃើញថាវៀតណាមបានរំលោភយកដីកម្ពុជា មានប្រសាសន៍ថា នេះបង្ហាញថាវៀតណាមមានចេតនាចង់រំលោភយកទឹកដីកម្ពុជា។ លោកជំរុញឲ្យរដ្ឋាភិបាលកម្ពុជាតាមដានការសន្យារបស់វៀតណាមដែលថានឹងលុបស្រះ និងប៉ុស្តិ៍យាមដែល

ខ្លួនបានសាងសង់នោះ។ លោកថាក្នុងករណីដែលវៀតណាមមិនព្រមធ្វើតាមការសន្យា កម្ពុជាគួរតែប្រើយន្តការប្ដឹងទៅអង្គការសហប្រជាជាតិអំពីបញ្ហាព្រំដែននេះ។

បើតាមសេចក្ដីប្រកាសព័ត៌មានរបស់ភាគីកម្ពុជាដែលសរុបលទ្ធផលនៃកិច្ចប្រជុំបីថ្ងៃឲ្យដឹងថាកិច្ចប្រជុំនេះបានដំណើរការប្រកបដោយបរិយាកាសស្និទ្ធស្នាល ឈរលើមូលដ្ឋាន និងស្មារតីគោរពគ្នាទៅវិញទៅមកនូវឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីនៃប្រទេសនីមួយៗ។ សេចក្ដីប្រកាសបន្តថា«*ភាគីទាំងពីរទទួលស្គាល់ថាការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរមានការស្មុគស្មាញច្រើន ទោះជាភាគីទាំងពីរបានបោះបង្គោលព្រំដែនបានចំនួនប្រមាណ៨៣ភាគរយរួចហើយក៏ដោយ។ ភាគីទាំងពីរបានឯកភាពគ្នានឹងខិតខំបញ្ចប់កិច្ចការព្រំដែនឲ្យបានចប់នាពេលខាងមុខ*»។

បើតាមសេចក្ដីប្រកាសព័ត៌មានភាគីទាំងពីរបានឯកភាពអនុវត្តឲ្យបានម៉ឺងម៉ាត់ តាមស្មារតីនៃសេចក្ដីប្រកាសព័ត៌មានរួម ចុះថ្ងៃទី១៧ខែមករា ឆ្នាំ១៩៩៥ ស្ដីពីការរក្សាស្ថានភាពបច្ចុប្បន្ននៅតាមបណ្ដោយព្រំដែន។ សេចក្ដីប្រកាសបន្ថែមថា«*ភាគីទាំងពីរឯកភាពឲ្យក្រុមបច្ចេកទេសចម្រុះព្រំដែន ក៏ដូចជាអាជ្ញាធរនៅតាមបណ្ដាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរសហការគ្នាដោះស្រាយឲ្យមានប្រសិទ្ធភាពរាល់បាតុភាពដែលកើតមានឡើងនៅតាមបណ្ដោយព្រំដែន ដើម្បីទប់ស្កាត់ និងបញ្ចៀសការរីករាលដាល ដែលនាំឲ្យប៉ះពាល់ដល់ទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ*»៕ រាយការណ៍បន្ថែមដោយទូច សុខា

សរសេរមកកាន់លោក ស៊ុន ណារិន តាមរយៈsun_narin@vodhotnews.com